# សំណាកផូស៊ីលសត្វសមុទ្របុរាណ
# (២៥១-២៩៩លានឆ្នាំ)

ការសិក្សាស្រាវជ្រាវផូស៊ីលក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមតាំងពីឆ្នាំ២០១៩រហូតមកដល់ពេលនេះ គឺបានរកឃើញស្ថានីយ៍ផូស៊ីលចំនួន២៤ទីតាំង។ ក្នុងនោះភ្នំដូងព្រះ ដែលស្ថិតនៅខេត្តបន្ទាយមានជ័យ ក៏ជាស្ថានីយ៍ផូស៊ីលមួយដែលបានរកសំណាកផូស៊ីលមួយចំនួនដ៏ជាទីចាប់អារម្មណ៍សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។ អត្ថបទនេះនឹងរៀបរាប់អំពីសំណាកផូស៊ីលសត្វសមុទ្របុរាណមួយ ដែលរកឃើញនៅទីតាំងខាងលើ ហើយសំណាកនេះនឹងគ្រោងដាក់តាំងបង្ហាញនាពេលខាងមុខ សម្រាប់ជាចំណេះដឹងដល់ប្រជាជនខ្មែរអំពី ផូស៊ីល (រូបលេខ១-២)។ សំណាកផូស៊ីលបានចុះលេខបញ្ជីសំណាក MOE.Fossil.01មានន័យថា ផូស៊ីល នៃក្រសួងបរិស្ថាន លេខ០១។




រូបលេខ១-២

សំណាកផូស៊ីលសត្វសមុទ្រមួយដុំ បានយកមកពីភ្នំដូងព្រះ ក្រុងសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យកាលពីឆ្នាំ២០១៩ (រូបលេខ៣)។ ដោយក្រុមការងារសិក្សាផូស៊ីល នៃនាយកដ្ឋានតំបន់បេតិកភណ្ឌ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ ផូស៊ីលនេះត្រូវបានយកពីផ្ទាំងថ្ម ក្បែរកូនភ្នំតូចមួយ ដែលត្រូវបានគេវាយយកថ្ម និងជាទីតាំងដែលគេយកអាចម៍ដី។

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ភ្នំដូងព្រះ ជាប្រភេទភ្នំថ្មកំបោរ និងលាយប្រភេទដីផ្សេងៗ ព្រមទាំងមានស្រទាប់ដីច្រើនដែលប្រែប្រួលទៅតាមសម័យកាល និងស្ថានភាពបរិស្ថានក្នុងសម័យកាលនីមួយៗ ។ ភ្នំនេះមានកម្ពស់ប្រមាណ៧០ម៉ែត្រធៀបពីនីវ៉ូទឹកសមុទ្រ និងធ្លាប់មានអតីតកាលនៅក្នុងសមុទ្រ។ យើងបានរកឃើញសំណាកផូស៊ីលសត្វសមុទ្រជាច្រើនប្រភេទ និងមានផូស៊ីលឈើថ្មផងដែរ ហើយត្រូវបានកំណត់អាយុកាល ក្នុងស័កទី១(Paleozoic) សម័យ Permian (251-299លានឆ្នាំ)[១]

សំណាកផូស៊ីលសត្វសមុទ្រ ដែលកកជាថ្មកំបោរ មានទំហំ ២៨ស.ម ទំងន់៣គ.ក្រ មានសត្វ៤ប្រភេទនៅក្នុងនោះ។ សត្វទាំងឡាយនេះបានរស់នៅក្នុងរយៈពេលមួយបានកកក្លាំងជាស្រទាប់ថ្មមួយដូចជា៖ Bryozoa, Fusulina, Verbeekina verbeeki, and Bivalve។

**១. Bryozoa**

ជាឈ្មោះសាខា (Phylum) មួយនៃអាណាចក្រសត្វ ដែលហៅថា Phylum Bryozoa ។ សម្រាប់ប្រជាជនកម្ពុជា គឺមិនបានហៅទៅតាមពាក្យបច្ចេកទេសទេ យើងតែងហៅថាផ្កាថ្មតែម្តង តែពួកវាស្ថិតនៅក្នុងសាខាផ្សេងគ្នា។ ផូស៊ីលដែលមើលទៅហាក់ដូចជាផ្កាថ្ម មានរាងវែងនិងមានបែកខ្នែងជាដើមចំនួន៤ (រូបលេខ១) វាស្ថិតនៅក្នុងសាខា Bryozoa នៃថ្នាក់ Stenolaemeta[២] និងមិនទាន់ដឹងអំពីឈ្មោះរបស់វានៅឡើយ។ វាអាចជា Bryozoa តែមួយដែលផ្នែកខាងគល់មានអង្កត់ផ្ចិត២.២ស.ម ដោយពួកនេះមានបែកខ្នែងច្រើន ដូចផ្កាថ្ម។

**២. Fusulina**

សត្វដែលមានសណ្ឋានដូចគ្រាប់អង្ករ ទំហំប្រមាណ៥ម.ម (រូបលេខ២) ។ យើងអាចកំណត់ Species ប្រភេទ Fusulina[៣] ស្ថិតនៅក្នុងគ្រួសារ (Family) Schwagerinidae លំដាប់ (Orders) Fusulinina សាខា (Phylum) Foraminifera បច្ចុប្បន្ននេះបានដាច់ពូជន៍។ ក្នុងសំណាកនេះ ពពួក Fusulina នេះមានចំនួនច្រើនដែលកកក្លាំងជាថ្ម មានចំនួនរាប់ម៉ឺន កកស្រោប Bryozoa និងបង្កើតបានជាស្រទាប់ថ្មដែលមានកម្រាស់ប្រមាណ៦ស.ម។

---

[១] General Department of Mineral Resource, 2010, Geological Map of Cambodia

[២] https://www.digitalatlasofancientlife.org/vc/bryozoa/

[៣] https://www.digitalatlasofancientlife.org/vc/foraminifera/

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

**៣. Verbeekina verbeeki**

សត្វដែលមានរាងជាដុំមូលៗតូចៗ ប្រមាណ៥ម.ម Verbeekina verbeeki[៤](រូបលេខ៥) ពពួកនេះក៏ស្ថិតនៅក្នុង សាខា (Phylum) Foraminifera ផងដែរ។ យើងឃើញពួកនេះរស់នៅលាយឡំជាមួយ Fusulina និង Bryozoa តែក៏មានចំនួនមិនច្រើន។ ចំណែកនៅផ្នែកម្ខាងទៀតនៃថ្ម ពួកនេះបានប្រមូលផ្ដុំកកជាស្រទាប់ថ្មម្ខាង ដែលមានចំនួនរាប់រយ។

**៤. ពពួក ង៉ាវ? ឬ Bivalve?**

វាអាចជាប្រភេទមួយនៃពពួកង៉ាវ តែវាមានការពិបាកក្នុងការពិនិត្យ ដោយវាមានទំហំតូច ពេលខ្លះក៏មានការច្រឡំគ្នានឹងពពួកសាខា (Phylum) Brachiopods ដែលទាមទារឱ្យមានការពិនិត្យលំអិត ហើយក៏អាស្រ័យនឹងផូស៊ីលមានលក្ខណៈគ្រប់គ្រាន់ដែរទេ(រូបលេខ៦)។

សរុបមក សំណាកផូស៊ីល MOE.Fossil.01 ដែលជាថ្មកំបោរ មានកម្រាស់៦ស.ម ជាបំណែកមួយនៃស្រទាប់ភ្នំ វាបានកើតឡើងដោយសារបណ្ដុំនៃសត្វ Fusulina ដូចគ្រាប់អង្ករដែលមានចំនួនច្រើនជាងគេ កកក្ដាំង ស្រោប Bryozoa ជាបន្តបន្ទាប់ ដោយលាយឡំនិង សត្វ Verbeekina verbeeki ដុំមូលៗតូចៗ និងង៉ាវ។ Bryozoa ដែលមានសណ្ឋានដូចផ្កាថ្មនោះ វារស់នៅលើស្រទាប់ដី ចំណែកពពួក Fusulina ពពួក Verbeekina verbeeki និង ង៉ាវ ជាពពួកដែលចល័តជាប្រចាំ។ ពពួក Fusulina បានកកជាបន្តបន្ទាប់បានជាស្រទាប់ដីមួយ ដែលក្នុងសម័យកាលមួយ ដែលមានបរិស្ថានដូចគ្នា ការកកនេះក៏បង្កើតបានជាស្រទាប់ដីមួយក្រាស់។ មួយផ្នែកទៀតពេលមួយពពួក Verbeekina verbeeki មានចំនួនច្រើន ក៏បានកកនៅផ្នែកម្ខាងនៃស្រទាប់នោះ និងក្រោយមកក៏បានក្លាយជាស្រទាប់ថ្មកំបោរ។ ពួកនេះរស់នៅក្នុងតំបន់តែមួយ និងមានជម្រៅទឹកមិនជ្រៅ ដែលពួកនេះអាចរស់នៅ និងអាចបង្កើតបានជាថ្មប៉ប្រះទឹក។ ក្រោយមកមានការផ្លាស់ប្ដូរបរិស្ថាននៃការរស់នៅ ដូចជាទឹករាក់ ឬ គោក ឬត្រល់ទៅទឹកជ្រៅវិញ ក៏បង្កើតបានជាស្រទាប់ថ្មី។

[៤] file:///C:/Users/TRC/Downloads/vangorsel2014_paleoz_faunas_floras_indonesia.pdf p.18



រូបលេខ៣៖ ទីតាំងផូស៊ីល



រូបលេខ៤៖ Fusulina

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ៥៖ សត្វ Verbeekina verbeeki



រូបលេខ៦៖ ងាវ?

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ